# មហាវិទ្យាល័យបុរាណវិទ្យា

## ១. ស្ថានភាពទូទៅ

មហាវិទ្យាល័យបុរាណវិទ្យាជាផ្នែកមួយនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មាននាទីបណ្តុះបណ្តាលធនធានមនុស្សថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតឲ្យមានការយល់ដឹងស៊ីជម្រៅទៅលើផ្នែកបុរេប្រវត្តិ, ប្រវត្តិវិទ្យា, ប្រវត្តិសិល្បៈ (បដិមាសាស្ត្រនិងសំណង់), នរវិទ្យា, សូរវិទ្យា ពោលគឺជំនាញខាងវប្បធម៌, ប្រវត្តិសាស្ត្រ និងប្រពៃណី។

មហាវិទ្យាល័យបុរាណវិទ្យាមានអគារចំនួន១ មានការអភិវឌ្ឍន៍កែលំអថ្មី (អភិរក្សលំនាំចាស់ ) មាន២ជាន់ ចែកចេញជាបន្ទប់តូចធំចំនួន១២ ក្នុងនោះមាន៖

- បន្ទប់សិក្សាស្អាតធំទូលាយប្រកបដោយផាសុខភាពចំនួន៥ បន្ទប់នីមួយៗនិស្សិតអង្គុយរៀនពី៣៥-៤៥ នាក់បាន, សាលសហសិក្សាចំនួន១ (អង្គុយបាន១០០នាក់ )។

-បន្ទប់ពិសោធន៍ចំនួន១ កំពុងរៀបចំឡើងវិញ, បន្ទប់សាស្ត្រាចារ្យចំនួន១ មានបំពាក់ម៉ាស៊ីនត្រជាក់ និងមាន Internet ប្រើប្រាស់។

-បន្ទប់ការិយាល័យចំនួន១ ចែកជាពីរបន្ទប់សម្រាប់ថ្នាក់ដឹកនាំមហាវិទ្យាល័យ និងមន្ត្រីរាជការបម្រើការ។

-បន្ទប់សម្រាប់អានសៀវភៅ (កំពុងរៀបចំ មានបំពាក់ម៉ាស៊ីនត្រជាក់ និងមាន Internet ប្រើប្រាស់ )ចំនួន១។

-សាលប្រជុំធំទូលាយបំពាក់ម៉ាស៊ីនត្រជាក់អាចអង្គុយបាន៨៥ នាក់ សម្រាប់ប្រជុំថ្នាក់ដឹកនាំសាកលវិទ្យាល័យ សម្រាប់ទទួលភ្ញៀវគណៈប្រតិភូសំខាន់ៗ សម្រាប់ប្រើប្រាស់ជាសាលសម្តែងសិល្បៈផង ជាពិសេសសម្រាប់ប្រើក្នុងពិធីការពារសារណានិស្សិតបញ្ចប់បរិញ្ញាបត្រជារៀងរាល់ឆ្នាំ។

-ឃ្លាំងចំនួន១ និងមានបន្ទប់អនាម័យស្អាត។

ក្នុងបន្ទប់រៀននីមួយៗមានសម្ភារៈប្រើប្រាស់ក្នុងការសិក្សាដូចជា តុនិងកៅអី, ក្តារខៀន, ផ្ទាំងសំពត់សសម្រាប់បញ្ចាំងរូប, ក្តារបិទផ្សាយពត៌មាន, ម៉ាស៊ីនបញ្ចាំងរូបភាព (LCD Projector) ចាប់ជាប់ជាអចិន្ត្រៃយ៍, ទូដាក់សម្ភារៈរៀនភាសាបារាំង ឧបករណ៍ជំនួយខាងសម្ទេង និងបំពង់ពន្លត់អគ្គីភ័យ។ល។

*បច្ចុប្បន្នមហាវិទ្យាល័យបាន និងកំពុងអនុវត្តការងាររបស់ខ្លួនយ៉ាងមមាញឹកតាមផែនការណែនាំរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏ដូចជាក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងទិសដៅដែលបានកំណត់។ (រូបលេខ១)*

## ២. ប្រវត្ត

*ការងារស្រាវជ្រាវនៅប្រទេសកម្ពុជានាសតវត្សរ៍ទី២០ មានការរីកចម្រើន និង ពេញនិយមជាខ្លាំងពីសំណាក់អ្នកស្រាវជ្រាវជាតិអឺរ៉ុប និង ទទួលបាននូវការគាំទ្រជាលំដាប់។ ដូច្នេះវិស័យនេះតម្រូវឲ្យមានការបង្កើតឡើងជាចាំបាច់នូវស្ថាប័នជាតិមួយក្នុងប្រទេសកម្ពុជា* ***គឺមហាវិទ្យាល័យបុរាណវិទ្យា*** *នៅឆ្នាំ១៩៦៥ ដោយមានភាតព្វកិច្ចបណ្តុះបណ្តាលនិស្សិត និងបន្តកិច្ចការស្រាវជ្រាវ។*

*មហាវិទ្យាល័យបុរាណវិទ្យាបង្កើតជាផ្លូវការក្នុងដំណាក់កាលទី១ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥ ក្នុងឱកាសនៃការរៀបចំពង្រីកសាលាវិចិត្រសិល្បៈ (សាលារចនា) ឲ្យក្លាយទៅជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលក្នុងនោះមានមហាវិទ្យាល័យចំនួន៥ ហើយដំណើរការរហូតដល់ឆ្នាំ១៩៧៥។ ក្នុងរយៈកាល១០ឆ្នាំ ចាប់ពីពេលបង្កើតមហាវិទ្យាល័យនេះដំបូងរហូតដល់ថ្ងៃបិទទ្វារបណ្តោះអាសន្ននោះ មាននិស្សិតចូលរៀនបាន៥ជំនាន់ សរុបចំនួនប្រហែល៧០នាក់។*

*ប្រទេសកម្ពុជាបានជួបវិបត្តិនូវសង្គ្រាមនៅទសវត្ស១៩៧០ និង១៩៨០ ធ្វើឲ្យរាំងស្ទះដល់វិស័យសិក្សាស្រាវជ្រាវ មហាវិទ្យាល័យបុរាណវិទ្យាត្រូវបិទទ្វារ។ ក្រោយពីផ្អាកការបណ្តុះបណ្តាលជាបណ្តោះអាសន្នក្នុងសម័យកាលមានសង្គ្រាមមក ទើបមានការរៀបចំបង្កើតមហាវិទ្យាល័យបុរាណវិទ្យាជាផ្លូវការឡើងវិញក្នុងដំណាក់កាលទី២ គឺនៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៨៨ ដោយការផ្តួចផ្តើមគំនិតរបស់អតីតនិស្សិតបុរាណវិទ្យាប្រមាណជា១០ រូបដែលនៅរស់រានមានជីវិតសល់ពីការកាប់សម្លាប់ក្នុងរបបប៉ុល ពត និងបានបន្តជាហូរហែមកដល់បច្ចុប្បន្ន។ តាំងពីបង្កើតឡើងវិញមកទល់នឹងឆ្នាំ២០១៤ មហាវិទ្យាល័យទទួលបាននិស្សិត២៥ជំនាន់ សរុបចំនួន៦៨៦នាក់ ហើយក៏កំពុងតែដំណើរការទៅមុខជាលំដាប់។*

## ៣. អំពីថ្នាក់ដឹកនាំ មន្ត្រីរាជការ

បច្ចុប្បន្នមហាវិទ្យាល័យបុរាណវិទ្យាមានមន្ត្រីរាជការសរុបចំនួន១៤ នាក់ (នារី ៦នាក់)៖

-ព្រឹទ្ធបុរស ១ នាក់ ជាអ្នកគ្រប់គ្រងទូទៅ និងព្រឹទ្ធបុរសរង៤ នាក់ (នារី ២ នាក់ )។

-មន្ត្រីជំនាញឯកទេសបុរាណវិទ្យាចំនួន ៥ នាក់ (នារី ២នាក់)។

-មន្ត្រីជំនាញស្ថាបត្យ និងនគរោបនីយវិទ្យាចំនួន ១ នាក់។

-មន្ត្រីជំនាញគុបតែងលំអនៃសិល្បៈសូនរូបចំនួន ១ នាក់។

-មន្ត្រីរដ្ឋបាលចំនួន ១ នាក់ (នារី ១នាក់)។

-ពលករអណ្តែតចំនួន ១ នាក់ (នារី ១ នាក់)។

ចន្លោះឆ្នាំ១៩៦៥ - ១៩៧៥ មានព្រឹទ្ធបុរសចំនួន៣ រូប ចូលធ្វើការបន្តបន្ទាប់គ្នា ហើយចាប់ពីឆ្នាំ១៩៨៨ មកដល់បច្ចុប្បន្នមានព្រឹទ្ធបុរសចំនួន៤ រូបទៀតគឺ៖

១. លោក ជា ថៃសេង ឆ្នាំ១៩៦៥ - ១៩៧១

២. លោក ទូច ពុយេតូ ឆ្នាំ១៩៧១ - ១៩៧៣

៣. លោក លី វូវឌង ឆ្នាំ១៩៧៣ - ១៩៧៥

៤. លោក ជុច ភឿន ឆ្នាំ១៩៨៨ - ១៩៩៦

៥. លោក ហោ ឡត ឆ្នាំ១៩៩៦ - ២០០៥

៦. លោក ផេង ស៊ីថា ឆ្នាំ២០០៥ - ២០១២

៧. លោក មួន សុភាព ឆ្នាំ២០១២ - បច្ចុប្បន្ន។ (រូបលេខ២)

រចនាសម្ព័ន្ធថ្នាក់ដឹកនាំមហាវិទ្យាល័យបច្ចុប្បន្នមាន៖

១. លោក មួន សុភាព ព្រឹទ្ធបុរស ទទួលបន្ទុករួម

២. លោក ហ៊ុន ថា ព្រឹទ្ធបុរសរង ទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ

៣. អ្នកស្រី សេង សុនេត្រា ព្រឹទ្ធបុរសរង ទទួលបន្ទុកផ្នែកសិក្សា និងបេឡា

៤. លោក ម៉ៅ ឈាងឡេង ព្រឹទ្ធបុរសរង ទទួលបន្ទុកស្រាវជ្រាវ ពត៌មាន និងផ្សព្វផ្សាយ

៥. អ្នកស្រី ទុយ ច័ន្ទសោភា ព្រឹទ្ធបុរសរង ទទួលបន្ទុកកិច្ចការរដ្ឋបាល។

## អំពីសាស្ត្រាចារ្យ

*សាស្ត្រាចារ្យនៅមហាវិទ្យាល័បុរាណវិទ្យាសព្វថ្ងៃមាន៣ប្រភេទ តាមបែបបទនៃការសិក្សាគឺ៖*

*ក- ថ្នាក់បរិញ្ញាបត្ររបស់មហាវិទ្យាល័យបុរាណវិទ្យា គឺមានសាស្ត្រាចារ្យសរុបចំនួន ៣៤ រូប និងគ្រូធ្វើបាឋកថាមួយចំនួនទៀត។ សាស្ត្រាចារ្យទាំងនោះមានជំនាញផ្សេងៗដូចជា៖ បុរេប្រវត្តិសាស្ត្រ, ប្រវត្តិសាស្ត្រ, ប្រវត្តិសិល្បៈ, សិលាចារឹក, អារ្យធម៌, នរវិទ្យា, សារមន្ទីរវិទ្យា, កុលាលភាជន៍, ភូគព្ភសាស្ត្រ, ជួសជុលនិងថែរក្សាវត្ថុបុរាណ, គ្រប់គ្រងបេតិកភណ្ឌ, ភាសាវិទ្យា, ភាសាសំស្ក្រឹត, ភាសាបាលី, មគ្គុទេសក៍បេតិកភណ្ឌ ៖*

*- សាស្ត្រាចារ្យសញ្ញាបត្របណ្ឌិតចំនួន៩ នាក់*

*- ស្ត្រាចារ្យសញ្ញាបត្រអនុបណ្ឌិតចំនួន១៦នាក់ (ស្រី១នាក់)*

*- សាស្ត្រាចារ្យសញ្ញាបត្របរិញ្ញាបត្រចំនួន៩នាក់ (ស្រី២នាក់) ជាសាស្ត្រាចារ្យដែលមានបទពិសោធន៍ការងារចាប់ពី១០ឆ្នាំឡើង។ ឯសាស្ត្រាចារ្យបង្រៀនផ្នែកភាសាបារាំងចំនួន ៨នាក់ ៖ សញ្ញាបត្របណ្ឌិត ១ នាក់ សញ្ញាបត្រអនុបណ្ឌិត ៧ នាក់ ( ស្រី ២ នាក់ )។*

*ទាំងសាស្ត្រាចារ្យខ្មែរ និងបរទេសអញ្ជើញមកពីស្ថាប័នផ្សេងៗរួមមាន ៖*

*- ទីស្តីការគណៈរដ្ឋមន្ត្រី*

*- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

*- អាជ្ញាធរអប្សរា (គ្រប់គ្រងតំបន់អង្គរ)*

*- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*

*- សារមន្ទីរជាតិ*

*- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

*- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ*

- និង AUF

*ខ- ថ្នាក់បរិញ្ញាបត្រផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី* MOUSSON *បង្រៀនក្នុងពេលវិស្សមកាល ដែលរៀបចំដោយវិទ្យាស្ថាន* INALCO *សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ឧបត្ថម្ភគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រ*

សិល្បៈ ក្រសួងអប់រំយុវជន និងកីឡា Institut de Recherche pour le Développement (IRD), Sedyl, AEFEK, AUF, IFC, ស្ថានទូតបារាំងប្រចាំនៅកម្ពុជា ព្រមទាំងស្ថាប័យស្រាវជ្រាវជាច្រើនទៀតនៃប្រទេសបារាំង។ កម្មវិធីនេះរៀនជាភាសាបារាំងសុទ្ធសាធ ហើយមាននិស្សិតមកពីប្រទេសបារាំង, ថៃឡង់ដ៍, ឡាវ និងប្រទេសដទៃទៀតក្នុងសហគមន៍អាស៊ានមកចូលសិក្សាផងដែរ។ បង្រៀនដោយសាស្ត្រាចារ្យល្បីៗដែលមានសញ្ញាបត្របណ្ឌិតមកពីប្រទេសបារាំង និងប្រទេសផ្សេងៗទៀត រួមជាមួយនឹងសាស្ត្រាចារ្យខ្មែរ សរុបចំនួន ១៩ រូប។

គ- ថ្នាក់អនុបណ្ឌិតផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON រៀបចំដោយវិទ្យាស្ថាន INALCO សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ឧបត្ថម្ភគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ ក្រសួងអប់រំយុវជន និងកីឡា Institut de Recherche pour le Développement (IRD), Sedyl, AEFEK, AUF, IFC, ស្ថានទូតបារាំងប្រចាំនៅកម្ពុជា ព្រមទាំងស្ថាប័យស្រាវជ្រាវជាច្រើនទៀតនៃប្រទេសបារាំង។ កម្មវិធីនេះរៀនជាភាសាបារាំងសុទ្ធសាធ ជាមួយសាស្ត្រាចារ្យល្បីៗអញ្ជើញមកពីប្រទេសបារាំងដែលមានសញ្ញាបត្របណ្ឌិត។

## ៤. អំពីនិស្សិត

បច្ចុប្បន្នមាននិស្សិតចូលរៀននៅមហាវិទ្យាល័យបុរាណវិទ្យារវាង២៥ - ៤៥នាក់ក្នុងមួយឆ្នាំ ហើយមានថ្នាក់រៀន៤កម្រិតសិក្សា គឺឆ្នាំទី១ដល់ឆ្នាំទី៤។ រីឯថ្នាក់អនុបណ្ឌិត រៀនរយៈពេលពីរឆ្នាំ គឺជំនាន់ទី១ មាននិស្សិតចំនួន១៦នាក់។

ក. ថ្នាក់បរិញ្ញាបត្រ

- និស្សិតអាហារូបករណ៍ ជ្រើសរើសក្នុងមួយឆ្នាំចំនួន៣០នាក់ ដែលមានលក្ខខណ្ឌប្រឡងជាប់បាក់ឌុបបាននិទ្ទេសរួម A-E, មុខវិជ្ជាប្រវត្តិសាស្ត្រ A-E, មុខវិជ្ជាភាសាខ្មែរ A-E ហើយត្រូវឆ្លងកាត់ការប្រឡងអំពីប្រវត្តិប្រាសាទ និង បុរាណដ្ឋាននៅកម្ពុជា រយៈពេល៦០នាទី។

- និស្សិតដែលរៀនផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON រៀនក្នុងពេលវិស្សមកាល ដែលរៀបចំដោយវិទ្យាស្ថាន INALCO រៀនជាភាសា

បារាំង តម្រូវឲ្យមានការប្រឡងជាចាំបាច់។

- និស្សិតបង់ថ្លៃថ្នាក់បរិញ្ញាបត្រ មានលក្ខខណ្ឌប្រឡងជាប់បាក់ឌុបបាននិទ្ទេសរួម A-E, មុខវិជ្ជាប្រវត្តិសាស្ត្រ A-E, មុខវិជ្ជាភាសាខ្មែរ A-E ហើយត្រូវបង់ប្រាក់ក្នុងឆ្នាំទី១ ចំនួន ៣០០ដុល្លារ, ឆ្នាំទី២, ទី៣, ទី៤ ចំនួន៤០០ដុល្លារក្នុងឆ្នាំនីមួយៗ។

ខ. ថ្នាក់អនុបណ្ឌិត

- និស្សិតអាហារូបករណ៍ថ្នាក់អនុបណ្ឌិតផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON ដែលរៀបចំដោយវិទ្យាស្ថាន INALCO រៀនជាភាសាបារាំង ទាល់តែបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកមនុស្សសាស្ត្រ ក្នុងកម្មវិធី MOUSSON ដោយតម្រូវឲ្យមានការប្រឡង និងបំពេញលក្ខខណ្ឌសិក្សាមួយចំនួនរបស់វិទ្យាស្ថាន INALCO នៃប្រទេសបារាំង។

- និស្សិតបង់ថ្លៃថ្នាក់អនុបណ្ឌិតផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON ដែលរៀបចំដោយវិទ្យាស្ថាន INALCO រៀនជាភាសាបារាំង។ និស្សិតត្រូវមានសញ្ញាបត្របរិញ្ញាបត្រ មានមុខវិជ្ជាប្រហាក់ប្រហែល និង មានចំណេះដឹងផ្នែកភាសាបារាំង។ រៀនរយៈពេល២ឆ្នាំ ដោយបង់ថ្លៃ៦០០ ដុល្លារ ក្នុង១ឆ្នាំ។

## ៥. អំពីឯកទេស

នៅមហាវិទ្យាល័យបុរាណវិទ្យាមានកម្មវិធីសិក្សារួមទូទៅតែម្តង ដែលទាក់ទងនឹងផ្នែកសំខាន់ៗដូចជា ៖

- ផ្នែកបុរេប្រវត្តិ៖ ទ្រឹស្តីបុរាណវិទ្យា, បុរេប្រវត្តិសាស្ត្រពិភពលោក, បុរេប្រវត្តិសាស្ត្រកម្ពុជា, ភូគព្ភសាស្ត្រស័កទី៤, កុលាលភាជន៍បុរាណ។

- ផ្នែកអារ្យធម៌ខ្មែរ៖ សិលាចារឹកភាសាខ្មែរបុរាណ, អារ្យធម៌ខ្មែរសម័យអង្គរ, ប្រវត្តិសាស្ត្រខ្មែរសម័យបុរាណ, ប្រវត្តិសាស្ត្រខ្មែរសម័យកណ្តាល, ប្រវត្តិសាស្ត្រខ្មែរសម័យថ្មី។

- ប្រវត្តិសិល្បៈ (បដិមាសាស្ត្រនិងសំណង់)៖ ប្រវត្តិសិល្បៈខ្មែរសម័យបុរាណ, ប្រវត្តិសិល្បៈខ្មែរសម័យកណ្តាល, ប្រវត្តិសិល្បៈឥណ្ឌា, ប្រវត្តិសិល្បៈឥណ្ឌូនេស៊ី, ប្រវត្តិសិល្បៈចាម្ប, ប្រវត្តិសិល្បៈទូទៅ។

- ផ្នែកនរវិទ្យា៖ នរវិទ្យាអាស៊ីអាគ្នេយ៍, នរវិទ្យាវប្បធម៌, កាលនរវិទ្យា, នរវិទ្យាប្រតិបត្តិ, វិធីសាស្ត្រស្រាវជ្រាវជាតិពន្ធុវិទ្យា។

- ផ្នែកអភិរក្ស៖ សារមន្ទីរវិទ្យា, អភិរក្សប្រាសាទបុរាណ, អភិរក្សនិងជួសជុលវត្ថុបុរាណធ្វើពីថ្ម, រក្សាវត្ថុបុរាណធ្វើពីលោហៈ, គ្រប់គ្រងបេតិកភណ្ឌ, ទស្សនៈអំពីការគ្រប់គ្រងបេតិកភណ្ឌ។

- ផ្នែកភាសា៖ សូរវិទ្យាទូទៅ, ភាសាសំស្ក្រឹត, ភាសាបាលី, ភាសាបារាំង។

- ផ្នែកមគ្គុទេសក៍បេតិកភណ្ឌ៖ ប្រវត្តិសាស្ត្រខ្មែរ, ប្រវត្តិសិល្បៈខ្មែរ, បដិមាសាស្ត្រ, ចម្លាក់ទេពកថា, ពិធីផ្សេងៗក្នុងប្រពៃណី, មគ្គុទេសក៍អនុវត្ត។

- ផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON ដែលរៀបចំដោយវិទ្យាស្ថាន INALCO រៀនជាភាសាបារាំង។

## ៦. កម្មវិធីសិក្សាក្នុងឆ្នាំនីមួយៗ

ការសិក្សាថ្នាក់បរិញ្ញាបត្រមានរយៈពេល៤ឆ្នាំ រៀនពេញមួយថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ហើយនៅឆមាសទី២នៃឆ្នាំទី៤ និស្សិតត្រូវធ្វើសារណាបញ្ចប់ការសិក្សា។ ក្រៅពីមុខវិជ្ជាសំខាន់ៗក្នុងកម្មវិធីសិក្សាប្រចាំឆ្នាំ នៅមានបាឋកថាបង្ហាញពីលទ្ធផលស្រាវជ្រាវ, បច្ចេកទេស ឬវិធីសាស្ត្រផ្សេងៗដោយអ្នកជំនាញជាតិនិងអន្តរជាតិតាមកម្រិតសិក្សាថ្នាក់នីមួយៗទៀតផង។

បន្ថែមលើកម្មវិធីសិក្សារបស់មហាវិទ្យាល័យបុរាណវិទ្យា និស្សិតអាចបន្តការសិក្សាផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON រៀននៅពេលវិស្សមកាល រៀបចំដោយវិទ្យាស្ថាន INALCO សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ឧបត្ថម្ភគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងអប់រំយុវជន និងកីឡា Institut de Recherche pour le Développement (IRD), Sedyl, AEFEK, AUF, IFC, ស្ថានទូតបារាំងប្រចាំនៅកម្ពុជា ព្រមទាំងស្ថាប័នស្រាវជ្រាវជាច្រើនទៀតនៃប្រទេសបារាំង។ កម្មវិធីនេះរៀនជាភាសាបារាំង ហើយមាននិស្សិតមកពីប្រទេសបារាំង, ថៃឡង់ដ៍, ឡាវ និងប្រទេសដទៃទៀតក្នុងសហគមន៍អាស៊ានមកចូលសិក្សាផងដែរ។ បង្រៀនដោយសាស្ត្រាចារ្យល្បីៗមកពីប្រទេសបារាំង និងប្រទេសផ្សេងៗទៀត។

និស្សិតនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ផ្នែកបុរាណវិទ្យា) សញ្ញាបត្រដែលទទួលស្គាល់ពីវិទ្យាស្ថាន INALCO នៃប្រទេសបារាំង និង សញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ និងស្រាវជ្រាវ នៃប្រទេសបារាំង ដែលមានការទទួលស្គាល់ជាអន្តរជាតិ។ និស្សិតអាចបន្តការសិក្សាថ្នាក់អនុបណ្ឌិត និងអាច ទទួលអាហារូបករណ៍ទៅសិក្សាបន្តនៅប្រទេសបារាំងទៀតផង។

កម្មសិក្សានៅតាមបុរាណដ្ឋាននានាតែងធ្វើឡើងទៅតាមកម្រិតឆ្នាំសិក្សាគឺ៖

- ថ្នាក់ឆ្នាំទី១ ចុះកម្មសិក្សាទៅបុរាណដ្ឋាននៅខេត្តតាកែវ និងកំពង់ធំ។
- ថ្នាក់ឆ្នាំទី២ ចុះកម្មសិក្សាទៅភូមិស្រុកក្នុងខេត្តកំពត, កែប ឬកំពង់ចាមជាដើម។
- ថ្នាក់ឆ្នាំទី៣ ចុះកម្មសិក្សាទៅបុរាណដ្ឋាននៅខេត្តព្រះវិហារ ឬកំពង់ចាម និងខេត្តកំពង់ឆ្នាំង។
- ថ្នាក់ឆ្នាំទី៤ ចុះកម្មសិក្សាទៅតំបន់អង្គរ ខេត្តសៀមរាប (រយៈពេល១០ថ្ងៃ)។

ក្រៅពីនោះមានកម្មសិក្សាជាច្រើនទៀត ដែលជាកម្មវិធីរបស់មហាវិទ្យាល័យខ្លះ និង ខ្លះទៀតជាកិច្ចសហការជាមួយនឹងស្ថាប័នផ្សេងៗ ៖

- កម្មសិក្សានៅសារមន្ទីរជាតិ ឬសារមន្ទីរខ្លះទៀត។
- កម្មសិក្សានៅរោងជាងជួសជុលវត្ថុបុរាណនៃសារមន្ទីរជាតិ និងក្រសួងវប្បធម៌និងវិចិត្រ សិល្បៈ។
- ប្រឡងចូលរួមធ្វើកំណាយស្រាវជ្រាវ ឬអភិរក្សប្រាសាទបុរាណនៅតំបន់អង្គរជាមួយ ស្ថាប័នអន្តរជាតិ។
- ប្រឡងចូលរួមធ្វើកំណាយស្រាវជ្រាវនៅតាមស្ថានីយបុរាណនានាជាមួយស្ថាប័នអន្តរជាតិ។
- ប្រឡងចូលរួមធ្វើការង៉ារស្រាវជ្រាវនៅតំបន់ផ្សេងៗ ជាមួយស្ថាប័នជាតិ ឬអន្តរជាតិ។ល។

(មានភ្ជាប់កម្មវិធីសក្សា ចំនួនក្រេឌីត...ក្នុងឆ្នាំសិក្សានីមួយៗ....)

## ៧. **កិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ** (ឈ្មោះស្ថាប័ន និងជំនាញ)

មហាវិទ្យាល័យខិតខំអភិវឌ្ឍ បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាមួយស្ថាប័នជាតិ និងអន្តរជាតិនានាដូចជា៖

- រាជបណ្ឌិត្យសភាកម្ពុជា

- អាជ្ញាធរអប្សរា (គ្រប់គ្រងតំបន់អង្គរ)

- អាជ្ញាធរជាតិព្រះវិហារ

- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- សារមន្ទីរជាតិ

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

- វិទ្យាស្ថាន INALCO នៃប្រទេសបារាំង

- AUF

- វិទ្យាស្ថាន NARA នៃប្រទេសជប៉ុន

- សាកលវិទ្យាល័យ Sophia នៃប្រទេសជប៉ុន

- សាកលវិទ្យាល័យ Sydney នៃប្រទេសអូស្ត្រាលី

- សាលាបារាំងចុងបូព៌ាប្រទេស ( EFEO )

- សាកលវិទ្យាល័យ Cologne នៃប្រទេសអាល្លឺម៉ង់....។ល។

## ៨. លទ្ធផល

- ការបណ្តុះបណ្តាល ៖

ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាក្លាយទៅជាអ្នកសិក្សាស្រាវជ្រាវ, ជាសាស្ត្រាចារ្យ, អ្នកគ្រប់គ្រងការងារបេតិកភណ្ឌវប្បធម៌, អ្នកអភិរក្សប្រាសាទ ឬបុរាណវត្ថុ, គ្រប់គ្រងសារមន្ទីរជាដើម។ រីឯស្ថាប័នដែលអាចចូលបម្រើការងារបានមានដូចជា៖

- ជាអ្នកស្រាវជ្រាវផ្នែកវប្បធម៌ និងប្រវត្តិសាស្ត្រ
- ធ្វើការនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ធ្វើការនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈតាមខេត្ត-ក្រុងនានា
- ធ្វើការនៅសារមន្ទីរទាំងឡាយ
- ធ្វើការនៅអាជ្ញាធរអប្សរា (គ្រប់គ្រងតំបន់អង្គរ)
- ធ្វើការនៅអាជ្ញាធរជាតិព្រះវិហារ (គ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ)

- ធ្វើការនៅស្ថាប័នជាតិ ឬអន្តរជាតិខាងកិច្ចការស្រាវជ្រាវផ្សេងៗ
- ធ្វើការក្នុងគម្រោងអន្តរជាតិ ខាងស្រាវជ្រាវ, អភិរក្សប្រាសាទ ឬបុរាណវត្ថុផ្សេងៗ។ល។
- និស្សិតមួយចំនួនកំពុងបន្តការសិក្សាកម្រិតបណ្ឌិតនៅបរទេស និងមួយចំនួនទៀតបាន បញ្ចប់ការសិក្សានៅក្រៅប្រទេសដោយជោគជ័យ។

**- ចំនួននិស្សិតដែលបានបញ្ចប់ ៖** និស្សិតដែលបានបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា (គិតត្រឹមឆ្នាំ២០១៤) មានចំនួន ២២ ជំនាន់ មាន ៥៩៥ នាក់។

**- ចំនួននិស្សិតដែលបានបញ្ចប់ ៖** និស្សិតដែលបានបញ្ចប់បរិញ្ញាបត្រផ្នែកមនុស្សសាស្ត្រ (នរវិទ្យា, ភាសាវិទ្យា, ប្រវត្តិសាស្ត្រ) ក្នុងកម្មវិធី MOUSSON មាន១ ជំនាន់ក្នុងនោះ មាន៖ និស្សិត ១៦ នាក់ (និស្សិតឡាវ ៣ នាក់) បានសញ្ញាបត្រទទួលស្គាល់ពីវិទ្យាស្ថាន INALCO នៃប្រទេសបារាំង និង ១៣ នាក់ បានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយ ក្រសួងអប់រំ និងស្រាវជ្រាវ នៃប្រទេសបារាំង។

## ៩. ផែនការនៃការបណ្តុះបណ្តាល

- អនាគតមហាវិទ្យាល័យនឹងខិតខំបន្តបេសកកម្មរបស់ខ្លួន ខិតខំពង្រីកកិច្ចសហការជាមួយ ស្ថាប័នអភិវឌ្ឍអន្តរជាតិបន្ថែមទៀត និងធ្វើយ៉ាងណាបន្តអនុវត្តកម្មវិធីសិក្សាកម្រិតថ្នាក់ អនុបណ្ឌិតផ្នែកមនុស្សសាស្ត្រ នូវកម្មវិធីខាងលើ ឲ្យទទួលបានជោគជ័យនាពេលខាងមុខ។
- ខិតខំពង្រីកជំនាញមគ្គុទេសក៍ទេសចរណ៍នៅក្នុងវិស័យវប្បធម៌ ដែលជាយន្តការទាក់ ទាញ ស្រូបយកនិស្សិតឲ្យចូលរៀនបានច្រើននៅមហាវិទ្យាល័យបុរាណវិទ្យា និងខិតខំ រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីនិស្សិតបុរាណមានលទ្ធភាពអាចប្រកបការងារផ្នែក ទេសចរណ៍វប្បធម៌ឲ្យបានទូលំទូលាយទៅតាមកម្រិតចំណេះដឹងថ្នាក់បរិញ្ញាបត្រ ដែល ឆ្លងកាត់ការសិក្សារហូតដល់ទៅ ៤ឆ្នាំ។
- មហាវិទ្យាល័យបុរាណវិទ្យាមានគំនិតចង់រំលេចឈ្មោះមហាវិទ្យាល័យនេះឲ្យទៅជា « មហាវិទ្យាល័យបុរាណវិទ្យា និងនរវិទ្យា » ដើម្បីឲ្យស្របតាមបេសកកម្មជាក់ស្តែងដែល យើងកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននេះ។